ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

# រវាង

# រោងចក្រ ថប ស៊ីលវើរ លីមីធីត

# និង

# តំណាងគ្រប់បុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ

# រោងចក្រ ថប ស៊ីលវើរ លីមីធីត

# ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២១ វេលាម៉ោង០១ និង ០០នាទីរសៀល នៅក្នុងក្រុមហ៊ុន ថប ស៊ីលវើរ លីមីធីត ( ស្វាយអន្ទរ ) មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត សហជីពមូលដ្ឋានប្រចាំក្រុមហ៊ុន ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងបច្ចុប្បន្នប្រឈមមុខខ្លាំងជាមួយបញ្ហាខ្វះវត្ថុធាតុដើមដែលចំណុចនេះហើយធ្វើអោយផលិតកម្មមួយចំនួនធំមិនមានការងារធ្វើតម្រូវអោយមានការព្យួរការងារ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ៧៦៣នាក់ ចាប់ពីថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០២១ រហូតដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២១ ។ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះកម្មករ និយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុនតាមលក្ខខណ្ឌដូចខាងក្រោម៖

- ចំនួន ១០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ចំនួន ២០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ចំនួន ៣០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ០១ខែ។

អង្គប្រជុំបានចប់វេលាម៉ោង ០៣ និង០០នាទីរសៀល នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និតស្នាលនិងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន ។

ស្វាយអន្ទរ.ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០២១

**តំណាងកម្មករ និង តំណាងសហជីព** | **នាយកក្រុមហ៊ុន**



គួច សុខជា



ទុំ គិលិន្ទ



ទ៊ី សម្បត្តិ



ម៉ូរ៉េ ចំពៅម៉ុន



តក់ស្រីឈួន



ស៊ិនឌុំ នា



សេងស្រីតាប